២កូរិនថូស១២:១៣-១៣:១៤

## សាវ័កប៉ុលចង់ធ្វើដំណើរទៅទីក្រុងកូរិនថូសម្តងទៀត

**១៣ តើអ្នករាល់គ្នាបានចាញ់ពួកជំនុំឯទៀត ទាំងប៉ុន្មានយ៉ាងណាខ្លះ
លើកចេញតែការដែលខ្ញុំមិនឱ្យអ្នកណាព្រួយនឹងខ្ញុំ សូមអត់ទោស
សេចក្តីកំហុសនេះឱ្យខ្ញុំផង ១៤ មើល ខ្ញុំរៀបនឹងមកឯអ្នករាល់គ្នា
ជាគំរប់៣លើកនេះហើយ ខ្ញុំក៏មិនឱ្យអ្នកណាព្រួយនឹងខ្ញុំទៀត
ដ្បិតខ្ញុំមិនរកចង់បានរបស់ទ្រព្យអ្នករាល់គ្នាទេ គឺរកតែខ្លួនអ្នករាល់
គ្នាប៉ុណ្ណោះ ដ្បិតមិនគួរឱ្យកូនចៅត្រូវប្រមូលទុកឱ្យឪពុកម្តាយទេ
គឺឪពុកម្តាយទេតើ ដែលត្រូវប្រមូលទុកឱ្យកូនវិញ (២កូរិនថូស
១២:១៣-១៤)។**

សាវ័កប៉ុលមានប្រសាសន៍ថា លោកជាឪពុកខាងព្រលឹងវិញ្ញាណដល់ពួកក្រុមជំនុំនៅទីក្រុងកូរិនថូស ពីព្រោះលោកបាននាំអ្នកទាំងនោះអោយជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

**ឯខ្ញុំៗសុខចិត្តនឹងចែកចាយ ហើយនឹងត្រូវហិនអស់រលីងទៅចុះ**

**ដោយព្រោះព្រលឹងរបស់អ្នករាល់គ្នា ថ្វីបើខ្ញុំស្រឡាញ់អ្នករាល់គ្នាកាន់តែខ្លាំងឡើងប៉ុណ្ណា នោះអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ក៏កាន់តែថយចុះប៉ុណ្ណោះដែរ (២កូរិនថូស១២:១៥)។**

លោកមានប្រសាសន៍ថា លោកស្រឡាញ់គេកាន់តែខ្លាំង គេស្រឡាញ់លោកកាន់តែតិច។ ទោះជាយ៉ាងនោះក៏ដោយ ព្រះវិញ្ញាណនៃព្រះបណ្តាលអោយលោកសរសេរពីទុក្ខលំបាកនៅលើផែនដីនេះ ជាជាងការបើកសម្តែងពីការអស្ចារ្យ ដែលលោកបានឃើញនៅស្ថានសួគ៌។

**ទោះបើដូច្នោះក៏ដោយ គង់តែខ្ញុំមិនបានឱ្យអ្នកណាមួយព្រួយនឹងខ្ញុំឡើយ តែដោយខ្ញុំឆ្លាត បានជាខ្ញុំចាប់អ្នករាល់គ្នា ដោយឧបាយកល (២កូរិនថូស១២:១៦)។**

លោកបញ្ជាក់ថា លោកចង់អោយពួកជំនុំទីក្រុងកូរិនថូស ថ្វាយដល់ព្រះអម្ចាស់យេស៊ូវ។ គំនិតនេះ ដូចព្រះហឫទ័យរបស់ព្រះអម្ចាស់យេស៊ូវដែរ។ ព្រះអង្គបង្គាប់ដល់ពួកសាវ័ក អោយធ្វើជាអ្នកនេសាទមនុស្ស។ ទ្រង់មានបន្ទូលថា "រួចទ្រង់មានបន្ទូលទៅគេថា ចូរមកតាមខ្ញុំៗនឹងតាំងអ្នក ឱ្យជាអ្នកនេសាទមនុស្សវិញ" (ម៉ាថាយ ៤:១៩)។

> **១៧ តើខ្ញុំបានចំណេញពីអ្នករាល់គ្នា ដោយសារអ្នកណាដែលខ្ញុំចាត់**
> **មកឬអី ១៨ ខ្ញុំបានអង្វរអ្នកទីតុសឱ្យមក ហើយបានចាត់បងប្អូនម្នាក់**
> **ឱ្យមកជាមួយដែរ តើទីតុសបានចំណេញពីអ្នករាល់គ្នាឬអី តើយើង**
> **ទាំង២នាក់មិនបានដើរដោយគំនិតតែ១ ហើយតាមដានជើង**
> **ដដែលទេឬអី (២កូរិនថូស១២:១៧-១៨)។**

សាវ័កប៉ុល ប្រើវិធីសាមញ្ញធម្មតាដើម្បីអធិប្បាយព្រះបន្ទូល អោយអ្នកស្តាប់ងាយយល់។ ដោយហេតុនោះ លោកមិនបញ្ជូនមនុស្សដទៃទៀត ក្រៅពីលោកទីតុស អោយនាំដំណឹងទៅ និងនាំដណឹងមកវិញរវាងពួកជំនុំទីក្រុងកូរិនថូស ហើយនិងរូបលោកផ្ទាល់ឡើយ។

> **១៩ មួយទៀត តើអ្នករាល់គ្នាគិតស្មានថា យើងខ្ញុំកំពុងតែដោះសា**
> **នឹងអ្នករាល់គ្នាឬអី ឱពួកស្ងួនភ្ងាអើយ យើងខ្ញុំនិយាយក្នុងព្រះ**
> **គ្រីស្ទនៅចំពោះព្រះ ហើយយើងខ្ញុំនិយាយគ្រប់ទាំងអស់នេះ**
> **សំរាប់នឹងស្អាងចិត្តអ្នករាល់គ្នាឡើងទេ ២០ ដ្បិតខ្ញុំខ្លាចក្រែងកាល**
> **ណាខ្ញុំមកដល់ នោះមិនឃើញអ្នករាល់គ្នា ដូចជាខ្ញុំចូលចិត្តនោះទេ**
> **ហើយអ្នករាល់គ្នាក៏មិនឃើញខ្ញុំ ដូចជាអ្នករាល់គ្នាចូលចិត្តដែរ**
> **ក្រែងកើតមានសេចក្តីឈ្លោះប្រកែក ឈ្នានីស គ្នាន់ក្នាញ់**

**ចាក់បែក បរិហារ បង្អាច់ ឆ្មើងឆ្មៃ ហើយរីកវរឡើង (២កូរិនថូស ១២:១៩-២០)។**

សាវ័កប៉ុលសង្ឃឹមថា ក្រុមជំនុំនៅទីនោះនឹងប្រព្រឹត្តទៅបានល្អ។ ឯពួកជំនុំក៏មានសេចក្ដីសង្ឃឹមវិញដែរ ថាលោកនឹងធ្វើការល្អចំពោះក្រុមជំនុំ។ ការសង្ឃឹមខ្លាំងពេកទាំងសងខាង ធ្វើអោយមានការវិវាទគ្នាកើតឡើង។

ខ្ញុំបម្រើព្រះអង្គអស់យូរឆ្នាំហើយ។ កាលខ្ញុំចាប់ផ្ដើមបម្រើព្រះអង្គដំបូង ខ្ញុំចូលចិត្តប្រកែកប្រណាំងពីគោលទ្ធិ ពីរបៀបធ្វើការ។ ឥឡូវខ្ញុំឈានមកដល់ចំណុចមួយដែលខ្ញុំលែងចង់ប្រកែកប្រណាំង យកឈ្នះយកចាញ់ជាមួយអ្នកណាទៀតហើយ។ បើជនណាមួយចង់យកឈ្នះលើខ្ញុំ សូមយកឈ្នះខ្លួនឯងចុះ។ បើលោកអ្នកយល់ថាខ្ញុំខុស សូមជួយអធិស្ឋានអោយព្រះជាម្ចាស់ អោយព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះតម្រង់គំនិតខ្ញុំផង។ ខ្ញុំយល់ថា ការប្រកែកប្រណាំឥតសម្រេចអ្វីបានក្រៅពីបង្ខាតពេល បង្ខាតវេលាក្នុងការផ្សព្វផ្សាយព្រះបន្ទូលរបស់ព្រះអង្គ។ ខ្ញុំមិនចង់ប្រកែកប្រណាំងអ្វីទេ គឺខ្ញុំចង់បានតែម្យ៉ាង គឺចង់បង្ហាត់បង្រៀនព្រះបន្ទូលរបស់ព្រះទាំងស្រុងតែម្ដង គឺពីគម្ពីរលោកុប្បត្តិដល់វិវរណៈមានចំនួន៦៦កណ្ឌ។

ម្យ៉ាងទៀតនៅក្នុងក្រុមជំនុំមានជនដែលប្រកាន់កិរិយាឆ្មើងឆ្មៃ។ គ្រូអធិប្បាយដ៏ល្បីល្បាញមួយរូបនាមបណ្ឌិតអាយរិនសាយ អោយឧទាហរណ៍ពីកិរិយាឆ្មើងឆ្មៃថាមានសត្វកង្កែបមួយក្បាលអង្គុយលើច្រាំងស្ទឹងកំពុងជន់។ កង្កែបនោះគិតក្នុងចិត្តថា

មើល គ្រាន់តែអញ្ជូអង្គុយនៅក្បែរច្រាំងស្ទឹង ទឹកស្ទឹងខ្លាចអញ្ជូរហូតដល់ជន់ពៀបច្រាំងផង។ ព្រានម្នាក់លបបាញ់កង្កែបនោះ។ គាប់ជួនគាត់ជាន់មែកឈើពុកបាក់ឮព្រាវ កង្កែបក៏ហក់ចូលទឹកដោយភ័យខ្លាច។ អ្នកមានចិត្តឆ្មើងឆ្មៃក្នុងក្រុមជំនុំ មានអាកប្បកិរិយាមិនខុសពីសត្វកង្កែបដែលអួតខ្លួនថាជាអ្នកធំឡើយ។ គ្រីស្ទបរិស័ទខ្លះយល់ថាខ្លួនមាននាទីធំណាស់គេគ្រប់គ្នាត្រូវស្តាប់ពាក្យរបស់គាត់។

នៅក្នុងក្រុមជំនុំក៏មានមនុស្សបង្កហេតុអោយវឹកវរឡើងដែរ។ ពេលគេខឹងសម្បានឹងនរណាម្នាក់ គេប្រមូលគ្នាចុះហត្ថលេខា ផ្តិតមេដៃធ្វើបាតុកម្មជាដើម។ គ្រីស្ទបរិស័ទប្រភេទនោះហើយ ដែលហៅថាជាគ្រីស្ទបរិស័ទបង្កហេតុអោយវឹកវរ។

**ក្រែងកាលណាខ្ញុំមកម្តងទៀត នោះព្រះនៃខ្ញុំនឹងបន្ទាបខ្ញុំនៅចំពោះអ្នករាល់គ្នា ហើយខ្ញុំនឹងត្រូវយំនឹងមនុស្សជាច្រើន ដែលធ្វើបាបពីមុន តែមិនបានប្រែចិត្តចេញ ពីសេចក្តីស្មោកគ្រោក សេចក្តីកំផិត នឹងសេចក្តីអាសអាភាស ដែលគេបានប្រព្រឹត្តនោះឡើយ (២កូរិនថូស១២:២១)។**

ទីក្រុងកូរិនថូសជាទីក្រុងដែលគេស្គាល់ថា បានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរជាងគេបំផុតនៅក្នុងចក្រភពរ៉ូមទាំងមូល។ សព្វថ្ងៃទីក្រុងធំៗ ដូចជាទីក្រុងឡាស់វេហ្គាស់ និងទីក្រុងរីណូ សុទ្ធតែជាក្រុងដែលមានសណ្ឋានដូចទីក្រុងកូរិនថូសដែរ។ អ្នកស្រុកនៅទី

នោះ នាំគ្នាប្រព្រឹត្តអំពើបាបដោយឥតញញើតដៃឡើយ។ បើមានអ្នកណាដើរឥតពាក់ខោអាវ គេយល់ថាអ្នកនោះជាមនុស្សក្លាហាន។

ក្រុមជំនុំទីក្រុងកូរិនថូសស្ថិតនៅក្នុងទីក្រុងដែលមានបាបប្រភេទនេះ។ ដោយសារដូច្នេះហើយ បានជាក្រុមជំនុំទីក្រុងកូរិនថូស ពិបាកលូតលាស់ជាងគេបំផុត នៅចក្រភពរ៉ូម។ តើក្រុមជំនុំសម័យសព្វថ្ងៃ មិនមានលក្ខណៈដូចជាក្រុមជំនុំកូរិនថូសទេឬ? បើយើងហ៊ានសារភាព ក្រុមជំនុំរបស់ព្រះអម្ចាស់យេស៊ូវសព្វថ្ងៃនេះ ក៏មានលក្ខណៈមិនខុសពីក្រុមជំនុំនៅទីក្រុងកូរិនថូសប៉ុន្មានទេ។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ក្រុមជំនុំរបស់ព្រះជាម្ចាស់នៅតែបំពេញតួនាទីរបស់ខ្លួន ជាអំបិលនិងពន្លឺនៃពិភពលោករបស់យើងនេះ។ ឧទាហរណ៍ថា ព្រះអម្ចាស់យេស៊ូវលើកយកពួកជំនុំរបស់ព្រះអង្គឡើងទៅស្ថានសួគ៌អស់ទៅ តើមានការអ្វីកើតឡើងនៅក្នុងលោកនេះ? នៅពេលនោះគ្រាមហាវេទនា ឈានចូលមកដល់។ ដូច្នេះ ដោយសារមានពួកជំនុំរបស់ព្រះអម្ចាស់យេស៊ូវ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ គង់នៅក្នុងក្រុមជំនុំទាំងនោះ។ ដោយសារមូលហេតុនោះហើយ បានជាក្រុមជំនុំអាចធ្វើជាអំបិលនិងពន្លឺនៃផែនដីយើងនេះ ទោះមិនសូវមានភាពបរិសុទ្ធក៏ដោយចុះ។

យើងសួរថា ដោយសារមានក្រុមជំនុំនៅលើពិភពលោកនេះ តើសកលលោកនេះមានភាពប្រសើរឡើង ឬក៏អាក្រក់ជាងមុន? បើតាមព្រះបន្ទូល មនុស្សអាក្រក់មួយជំនាន់ស្លាប់ មនុស្សអាក្រក់មួយជំនាន់ទៀតបានកើតឡើង។ ខ្ញុំយល់ថា ពិភពលោកសព្វថ្ងៃនេះគ្រាន់បើជាងកាលពីរពាន់ឆ្នាំកន្លងទៅ។ កាលណោះ គេយកព្រះអម្ចាស់

យេស៊ូវទៅឆ្កាង ហើយព្រះអម្ចាស់ទ្រង់អធិស្ឋានដល់ព្រះវរបិតាថា "ឯព្រះយេស៊ូវ ទ្រង់មានបន្ទូលថា ឱព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ដ្បិតគេមិនដឹងជាគេធ្វើអ្វីទេ គេក៏នាំគ្នាធ្វើឆ្នោតចាប់ព្រះពស្ត្រទ្រង់ចែកគ្នា" (លូកា២៣:៣៤)។

មនុស្សលោកសម័យដើម គេឆ្កាងព្រះរាជបុត្រារបស់ព្រះជាម្ចាស់។ ខ្ញុំយល់ថាមនុស្សលោកសព្វថ្ងៃនេះ កំពុងបដិសេធមិនទទួលព្រះអម្ចាស់យេស៊ូវ ដោយចាប់ព្រះអង្គឆ្កាងរៀងរាល់ថ្ងៃដែរ។ ដូច្នេះ អំពើបាបធំជាងគេបង្អស់ដែលមនុស្សលោកបានប្រព្រឹត្ត គឺអំពើបាបបដិសេធព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ មនុស្សមួយជំនាន់ៗ ដែលធ្លាប់រស់នៅលើពិភពលោកនេះសុទ្ធតែជាប់ពិរុទ្ធ ដោយបដិសេធព្រះអម្ចាស់យេស៊ូវ។ ព្រះអម្ចាស់យេស៊ូវមានបន្ទូលថា ពេលព្រះវិញ្ញាណបរិសុទ្ធយាងមក ព្រះអង្គទ្រង់ពន្យល់អោយមនុស្សលោកស្គាល់ពីអំពើបាប។ ឯអំពើបាបដែលព្រះអម្ចាស់យេស៊ូវមានបន្ទូលនេះ គឺជាអំពើបាបដែលគម្ពីរយ៉ូហាន១៦:៩សម្តែងថា "គឺពីអំពើបាប ដោយព្រោះគេមិនជឿដល់ខ្ញុំ"។

ម្យ៉ាងទៀត ពិភពលោកសព្វថ្ងៃនេះ មានលក្ខណៈល្អប្រសើរជាងកាលពីរពាន់ឆ្នាំកន្លងទៅ ពីព្រោះយើងអាចរស់នៅដោយសុខសាន្ត យើងមានការសប្បាយខ្លះៗ ឯវត្ថុដែលយើងប្រើប្រាស់សព្វថ្ងៃ ក៏ទំនើបជាងពេលមុនឆ្ងាយណាស់ដែរ។ ប៉ុន្តែ ក្រុមជំនុំត្រូវយល់ថា ភារៈរបស់យើង មិនមែនជាសួនច្បារសម្រាប់តុបតែងពិភពលោកនេះទេ។ ភារៈរបស់ពួកអ្នកជឿរៀងរាល់រូប គឺត្រូវផ្សាយដំណឹងល្អពីព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ឯការផ្សាយដំណឹងល្អនេះទៀតសោត គឺត្រូវផ្សាយទាំងពាក្យសម្តី ទាំង

កិរិយាប្រព្រឹត្ត អំពើសុចរិត។

ពួកជំនុំរបស់ព្រះអង្គ ជាសង្គមមនុស្សដែលប្រព្រឹត្តសេចក្តីសុចរិតរបស់ព្រះ។ យើងរស់នៅក្នុងជីវិតមួយ ដែលសម្តែងថាព្រះជាម្ចាស់គង់ជាមួយយើង។ ខ្ញុំចង់បញ្ជាក់ចំណុចនេះម្តងទៀតថា យើងជាមនុស្សមួយពួក ដែលត្រូវរស់ធ្វើបន្ទាល់ពីសេចក្តីសុចរិតនៃព្រះ។ បរាជ័យមួយនេះយើងជួបប្រទះយ៉ាងដំណំ ពោលគឺយើងពូកែនិយាយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប៉ុន្តែ មិនឃើញមានការអ្វីប្លែកសោះនៅក្នុងជីវិតរបស់យើង ក៏ដូចជានៅក្នុងសង្គមពួកអ្នកជឿដែរ។ ដោយសារមូលហេតុនោះហើយ បានជាមនុស្សលោក ដើរក្បែរក្រុមជំនុំរបស់ព្រះជាម្ចាស់ គេមិនដឹងថាទីនោះជាក្រុមជំនុំផង។ ក្រុមជំនុំរវល់តែនឹងការឈ្នានីស គ្នាន់ក្នាញ់ ឈ្លោះ ប្រកែក បែកបាក់ បរិហារបង្កាច់ ឆ្មើងឆ្មៃ និងរឹករវរ។

ប៉ុន្តែ ទោះបីក្រុមជំនុំរបស់ព្រះជាម្ចាស់មានលក្ខណៈបែបនោះក៏ដោយ ក្រុមជំនុំជាទីស្រឡាញ់របស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះអង្គបានទិញក្រុមជំនុំដោយព្រះលោហិតរបស់ទ្រង់។ ព្រមទាំងលាងសម្អាតក្រុមជំនុំ ដោយព្រះលោហិត ដើម្បីអោយព្រះវរបិតាបានទទួលក្រុមជំនុំនោះ ជាក្រុមជំនុំឥតស្លាកស្នាម ឥតជ្រួញអ្វីឡើយ។ ក្រុមជំនុំដែលព្រះជាម្ចាស់សម្អាតរួចហើយ គួរតែជាក្រុមជំនុំដែលរស់នៅធ្វើជាទីបន្ទាល់ពីព្រះជាម្ចាស់។ ផ្ទុយទៅវិញ យើងជាក្រុមជំនុំរស់នៅដាច់ឆ្ងាយពីទិសដៅនោះខ្លាំងណាស់។

# ជំពូក ១៣

***ឆាចចនា*** *ការពង្រឹងសិទ្ធិលោកប៉ុល*
*ជាសាវ័ករបស់ព្រះជាម្ចាស់*

## សាវ័កប៉ុលប្រើសិទ្ធិលោកជាសាវ័ក

**នេះជាគំរប់៣ដងហើយ ដែលខ្ញុំមកឯអ្នករាល់គ្នា គ្រប់ការទាំងអស់នឹងបានសំរេច ដោយនូវមាត់ស្មរបន្ទាល់២ឬ៣នាក់ (២កូរិនថូស១៣:១)។**

សាវ័កប៉ុលមានប្រសាសន៍ម្តងហើយម្តងទៀតពីដំណើរនេះ ដូចលោកបានមានប្រសាសន៍កន្លងមក។ លោកបញ្ជូនមនុស្សទៅទីក្រុងកូរិនថូសជាលើកទីបី ដើម្បីបញ្ជាក់ថា លោកអាចប្រើសិទ្ធិរបស់លោកជាសាវ័កមកលើពួកជំនុំនៅទីក្រុងនោះ។ ទោះបីជាពាក្យសម្តី ដែលលោកផ្តាំផ្ញើតាមគេ ទោះបីជាសំបុត្រក៏ដោយ លោកសរសេរទៅកាន់ពួកជំនុំនៅទីនោះ ក្នុងនាមលោកជាសាវ័ករបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ លោកមិនចង់លាក់បាំងអ្វីដល់ពួកជំនុំនេះទៀតទេ គឺលោកអនុវត្តសិទ្ធិរបស់លោកក្នុងនាមលោកជាសាវ័ករបស់ព្រះអម្ចាស់យេស៊ូវ ដើម្បីអោយពួកជំនុំនៅទីក្រុងកូរិនថូស

ដឹងខ្លួនថា លោកប្រើសិទ្ធិនេះដោយចេស្ដារបស់ព្រះអម្ចាស់។

> **[២]ខ្ញុំបានប្រាប់កាលពីដើម ហើយឥឡូវនេះក៏និយាយទុកជាមុន ទុកដូចជាកាលបាននៅជាមួយនឹងអ្នករាល់គ្នា ក្នុងលើកទី២នោះនៅឡើយ ហើយសព្វថ្ងៃនេះដែលនៅឃ្លាតគ្នា ខ្ញុំសរសេរមកពួកអ្នកនោះ ដែលធ្វើបាបពីមុន ហើយទៅអ្នកឯទៀតទាំងអស់ដែរថា បើខ្ញុំមកម្តងទៀត នោះខ្ញុំមិនប្រណីទេ [៣]ដ្បិតអ្នករាល់គ្នារកភស្តុតាងពីព្រះគ្រីស្ទ ដែលទ្រង់មានបន្ទូលដោយសារខ្ញុំ (ដែលទ្រង់មិនខ្សោយចំពោះអ្នករាល់គ្នា គឺមានព្រះចេស្ដាក្នុងអ្នករាល់គ្នាវិញ (២កូរិនថូស១៣:២-៣)។**

សាវ័កប៉ុលមានប្រសាសន៍ថា ខ្ញុំមកឯអ្នករាល់គ្នាដោយសេចក្តីទន់ខ្សោយ តែព្រះបន្ទូលព្រះដែលនៅក្នុងខ្លួនខ្ញុំ មានចេស្ដាយ៉ាងខ្លាំង អាចមានលទ្ធភាពបំផ្លាស់បំប្រែទីក្រុងកូរិនថូស ដែលពោរពេញទៅដោយអំពើបាប អោយមកជាទីក្រុងដែលល្អវិញបាន។

> **នោះបើទ្រង់ត្រូវគេឆ្កាង ដោយសេចក្តីកំសោយក៏ដោយ គង់តែទ្រង់មានព្រះជន្មរស់នៅដោយព្រះចេស្ដានៃព្រះដែរ ព្រោះយើង**

**ខ្ញុំខ្សោយក្នុងទ្រង់មែន តែយើងខ្ញុំនឹងរស់នៅជាមួយនឹងទ្រង់ ដោយសារព្រះចេស្តានៃព្រះ ដែលផ្តល់មកអ្នករាល់គ្នាវិញ) (២កូរិនថូស១៣:៤)។**

សាវ័កប៉ុលបញ្ជាក់ថា "ទោះបើទ្រង់ត្រូវគេឆ្កាង ដោយសេចក្តីកំសោយក៏ដោយ..."។ ខនេះមើលទៅហាក់ដូចជាព្រះមានសេចក្តីទន់ខ្សោយ។ តើព្រះជាម្ចាស់សម្តែងទ្រង់ទ្រាយបែបណា បានជាមនុស្សលោកយើងឃើញថាទ្រង់ខ្សោយ? សេចក្តីទន់ខ្សោយរបស់ព្រះជាម្ចាស់ គឺត្រង់ចំណុចដែលទ្រង់ព្រមអោយគេធ្វើគុតទ្រង់នៅលើឈើឆ្កាង។ ប៉ុន្តែ ទោះបីយើងមើលទៅ ហាក់ដូចជាព្រះអង្គមានសេចក្តីទន់ខ្សោយមែនតែ "...ទ្រង់មានព្រះជន្មរស់នៅដោយព្រះចេស្តានៃព្រះ..."។

**ចូរអ្នករាល់គ្នាពិចារណាខ្លួនឯងមើល តើស្ថិតនៅក្នុងសេចក្តីជំនឿឬទេ ចូរល្បងខ្លួនមើលចុះ តើអ្នករាល់គ្នាមិនយល់ឃើញថាព្រះយេស៊ូវគ្រីស្ទគង់ក្នុងអ្នករាល់គ្នាទេឬអី លើកតែអ្នករាល់គ្នាត្រូវកាត់ចោលចេញប៉ុណ្ណោះ (២កូរិនថូស១៣:៥)។**

ខគម្ពីរខាងលើ ទាក់ទងគោលទិស្តីពីការទទួលព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដោយប្រើឆន្ទៈសេរី ឬដោយការជ្រើសរើសទុកជាមុន។ សាវ័កប៉ុលមានប្រសាសន៍អោយពួក

ជំនុំពិចារណាខ្លួនឯងមើល តើស្ថិតនៅក្នុងជំនឿងដែរឬទេ? ក្នុងនាមយើងជាអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវ យើងត្រូវគិតគូរពីបញ្ហានេះជានិច្ច ដរាបណាយើងមានជីវិតរស់នៅ។ បើយើងមិនមែនជាអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវទេ យើងមិនចាំបាច់ពិចារណាខ្លួនឯង ថាតើពិតជាស្ថិតនៅក្នុងសេចក្តីជំនឿដែរឬ បើយើងគ្រាន់តែដើរតួជាអ្នកគ្រីស្ទានប៉ុណ្ណោះ យើងមិនចាំបាច់ពិចារណាពីដំណើរនេះឡើយ។

ហេតុអ្វីបានជាយើងចាំបាច់ពិចារណាពីដំណើរនេះ? រឿងនេះ ជារឿងឃើញសឃើញខ្មៅ សម្រាប់ជីវិតយើង។ បើយើងមិនជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ យើងគ្មានចំណែកជាមួយនឹងព្រះអម្ចាស់យេស៊ូវនៅស្ថានសួគ៌ឡើយ។ បើយើងជឿដល់ព្រះអម្ចាស់យេស៊ូវ យើងមានចំណែកជាមួយនឹងព្រះអង្គនៅស្ថានសួគ៌អស់កល្បជានិច្ច។ យើងត្រូវពិចារណាខ្លួនឯងមើល តើយើងពិតជាស្ថិតនៅក្នុងជំនឿលើព្រះយេស៊ូវគ្រីស្ទមែនដែរឬទេ?

**តែខ្ញុំសង្ឃឹមថា អ្នករាល់គ្នានឹងដឹងថា យើងខ្ញុំមិនត្រូវកាត់ចោលចេញទេ (២កូរិនថូស១៣:៦)។**

សាវ័កប៉ុលបានពិចារណាមើលខ្លួនលោករួចហើយ។ លោកចង់អោយគ្រីស្ទបរិស័ទគ្រប់រូបពិចារណាមើលខ្លួនឯងដែរ ក្រែងលោមិនមានជំនឿលើព្រះអម្ចាស់យេស៊ូវ។

**ហើយខ្ញុំអធិស្ឋានដល់ព្រះ សូមកុំឱ្យអ្នករាល់គ្នាធ្វើការអាក្រក់អ្វីឡើយ មិនមែនដើម្បីឱ្យយើងខ្ញុំបានរាប់ជាគួរទេ គឺប្រយោជន៍ឱ្យអ្នករាល់គ្នាបានប្រព្រឹត្តសេចក្ដីល្អតែប៉ុណ្ណោះ ហើយឱ្យយើងខ្ញុំទុកដូចជាត្រូវកាត់ចេញវិញចុះ (២កូរិនថូស១៣:៧)។**

សាវ័កប៉ុលចង់អោយពួកជំនុំនៅទីក្រុងកូរិនថូស អនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។

**ដ្បិតយើងខ្ញុំពុំអាចនឹងធ្វើអ្វី ទាស់នឹងសេចក្ដីពិតបានទេ ធ្វើបានតែអ្វីដែលសំរាប់សេចក្ដីពិតវិញ (២កូរិនថូស១៣:៨)។**

សេចក្ដីខាងលើ ជាសេចក្ដីពិតដ៏ធំមួយដែលយើងទាំងអស់គ្នាត្រូវដៅចំណាំអោយបានច្បាស់លាស់។ លោកអ្នកបងប្អូន យើងមិនអាចធ្វើអ្វីទាស់នឹងសេចក្ដីពិតបានទេ។ មនុស្សខ្លះប្រកែកប្រណាំងថា ព្រះបន្ទូលដែលមាននៅក្នុងព្រះគម្ពីរ មិនមែនជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ អ្នកប្រកែកប្រណាំងទាំងនោះ មិនអាចធ្វើអ្វីទាស់ទទឹងនឹងសេចក្ដីពិតបានទេ។ ព្រះជាម្ចាស់មិនត្រូវការអោយយើងការពារព្រះបន្ទូលរបស់ព្រះអង្គទេ។ មុខការរបស់យើង គឺត្រូវប្រគល់ព្រះបន្ទូលអោយមនុស្សឯទៀត តាមពេលវេលានិងកម្លាំងយើងអាចធ្វើទៅបាន។

**ពីព្រោះយើងខ្ញុំមានសេចក្ដីអំណរ ក្នុងកាលដែលយើងខ្ញុំខ្សោយ ហើយអ្នករាល់គ្នាមានកំឡាំងឡើង តែយើងខ្ញុំអធិស្ឋានសូម សេចក្ដីនេះទៀត គឺឲ្យពួកអ្នករាល់គ្នាបានគ្រប់លក្ខណ៍ទាំងអស់គ្នា (២កូរិនថូស១៣:៩)។**

"...ឲ្យពួកអ្នករាល់គ្នាបានគ្រប់លក្ខណ៍ទាំងអស់គ្នា" ត្រង់នេះមិនមែនមានន័យថា យើងជាមនុស្សគ្រប់លក្ខណ៍នោះទេ គ្រាន់តែមានន័យថា អោយយើងមានភាពចាស់ទុំនៅក្នុងសេចក្ដីជំនឿរបស់យើង។ សាវ័កប៉ុល ចង់អោយពួកជំនុំនៅទីក្រុងកូរិនថូស ដុះលូតលាស់រហូតមានភាពចាស់ទុំនៅក្នុងជំនឿ។

**ហេតុនោះបានជាកាលខ្ញុំនៅឃ្លាតពីអ្នករាល់គ្នា នោះខ្ញុំធ្វើសំបុត្រនេះ ក្រែងកាលណាខ្ញុំមកនៅជាមួយ នោះខ្ញុំនឹងប្រព្រឹត្តនឹងអ្នករាល់គ្នាដោយតឹងរ៉ឹង តាមអំណាចដែលព្រះអម្ចាស់បានប្រទានមកខ្ញុំ គឺសំរាប់នឹងស្អាងចិត្តឡើង មិនមែននឹងផ្តួលទេ (២កូរិនថូស ១៣:១០)។**

នៅក្នុងពេលនេះ សាវ័កប៉ុលមានចិត្តរីករាយក្នុងការសរសេរសំបុត្រទៅកាន់ពួកជំនុំនៅទីក្រុងកូរិនថូស។ លោកសរសេរទៅកាន់ពួកជំនុំនៅទីនោះ មិនមែនដើម្បី

បំផ្លិចបំផ្លាញគេទេ គឺលោកសរសេរដើម្បីលើកគេឡើង បញ្ឍូរគេឡើង និងតាំងគេ អោយបានខ្ពស់ឡើង។

## សេចក្តីសរុបនាក់ទងនឹងនាទីរបស់លោកប៉ុលជាសាវ័ក

**ឯសេចក្តីឯទៀត បងប្អូនអើយ ចូរមានសេចក្តីអំណរ ចូរឱ្យបាន គ្រប់លក្ខណ៍ ចូរឱ្យមានចិត្តក្សេមក្សាន្ត ចូរមានគំនិតដូចគ្នា ចូរនៅ ដោយមេត្រីនឹងគ្នាចុះ នោះព្រះនៃសេចក្តីស្រឡាញ់ នឹងសេចក្តី សុខសាន្ត ទ្រង់នឹងគង់នៅជាមួយនឹងអ្នករាល់គ្នា (២កូរិនថូស ១៣:១១)។**

សាវ័កប៉ុលមានប្រសាសន៍ម្តងទៀតថា "...ចូរឱ្យបានគ្រប់លក្ខណ៍..."។ ពាក្យ នេះមានន័យថា ចូរធ្វើជាមនុស្សចាស់ឡើង។ សូមកុំអោយពួកជំនុំនៅទីនោះ នៅតែ ជាគ្រីស្ទបរិស័ទកូនង៉ែតតទៅទៀត។ សព្វថ្ងៃនេះ យើងចង់អោយក្រុមជំនុំដែលជាអ្នក ជឿដល់ព្រះអម្ចាស់យេស៊ូវគ្រប់រូប មានភាពចាស់ចិត្តចាស់គំនិតក្នុងសេចក្តីជំនឿរបស់ ខ្លួនឡើង។

ម្យ៉ាងវិញទៀតសាវ័កប៉ុលមានប្រសាសន៍ថា "...ចូរឱ្យមានចិត្តក្សេម ក្សាន្ត..."។ ពាក្យក្សេមក្សាន្តមានន័យថា ទទួលជំនួយពីព្រះជាម្ចាស់។ ព្រះជាម្ចាស់ទ្រង់

បានហៅយើងថា ជាកូនរបស់ទ្រង់។ ទ្រង់យាងទន្ទឹមនឹងយើង ជួយយើង លើកទឹកចិត្តយើង ជំរុញចិត្តយើង ដើម្បីអោយយើងមានជ័យជំនះនៅក្នុងជីវិត។ ទោះបីលោកជាជនណា នៅទីណា ឬលោកអ្នកកំពុងឆ្លងស្ថានភាពបែបណានៅក្នុងជីវិតក៏ដោយចុះ ព្រះជាម្ចាស់មានព្រះហឫទ័យចង់ជួយដល់លោកអ្នក។ តើព្រះអង្គជួយដល់យើងដោយវិធីណា? ព្រះអង្គជួយយើងដោយប្រើព្រះវិញ្ញាណបរិសុទ្ធពន្យល់យើង អោយយើងយល់ព្រះបន្ទូលដែលយើងអាន។

"...ចូរមានគំនិតដូចគ្នា..." យើងត្រូវមានគំនិតរបស់ព្រះយេស៊ូវគ្រីស្ទ នៅក្នុងគំនិតរបស់យើង។

"...ចូរនៅដោយមេត្រីនឹងគ្នាចុះ..." យើងមិនអាចបង្កើតអោយមានសេចក្តីមេត្រី ឬសន្តិភាពបានទេ ប៉ុន្តែ យើងអាចរស់នៅក្នុងសេចក្តីសុខសាន្តសន្តិភាពបាន។

"...នោះព្រះនៃសេចក្តីស្រឡាញ់ នឹងសេចក្តីសុខសាន្ត ទ្រង់នឹងគង់នៅជាមួយនឹងអ្នករាល់គ្នា"។ ហេតុការណ៍ដែលព្រះជាម្ចាស់គង់នៅជាមួយយើង ញ៉ាំងអោយយើងមានសេចក្តីសុខនៅក្នុងចិត្ត លើសពីហេតុការណ៍ ដែលចិត្តយើងអាចយល់បាន។ សេចក្តីសុខនេះកើតឡើងដោយសារព្រះអម្ចាស់យេស៊ូវ បង្ហូរព្រះលោហិតរបស់ទ្រង់ជំនួសអំពើបាបរបស់យើងនៅលើឈើឆ្កាង។ យើងត្រូវរស់នៅដោយក្នុងសេចក្តីសុខសាន្ត ដែលព្រះជាម្ចាស់ប្រទានមកយើង។

**សូមជំរាបសួរគ្នាទៅវិញទៅមក ដោយថើបយ៉ាងបរិសុទ្ធ (២កូរិនថូស១៣:១២)។**

ខ្ញុំសូមនិយាយរឿងពិតមួយ ដែលកើតឡើងទាក់ទងនឹងខគម្ពីរខាងលើ។ មានបាវបម្រើរបស់ព្រះជាម្ចាស់មួយរូបនាមបណ្ឌិត វ៉ែលទ័ររៀលសុន។ លោកជាបាវបម្រើដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់។ មិត្តភក្តិរបស់លោកប្រុសៗដូចគ្នា គោរពលោកខ្លាំងណាស់ ពីព្រោះលោកជាបាវបម្រើដ៏បរិសុទ្ធរបស់ព្រះអម្ចាស់។ ពេលជួបគាត់ គេតែងតែថើបគាត់ដោយសេចក្តីស្រឡាញ់។ ប៉ុន្តែ នៅពេលដែលមិត្តភក្តិប្រុសរបស់លោកថើបប្រពន្ធរបស់គាត់វិញ គេមានអារម្មណ៍ផ្សេង។ មិត្តភក្តិរបស់លោកមានប្រសាសន៍ថា "បណ្ឌិតរៀលសុន ពេលខ្ញុំថើបលោកដោយបរិសុទ្ធ ខ្ញុំមានអារម្មណ៍ដូចជាស្និទ្ធស្នាលខ្លាំងណាស់។ ប៉ុន្តែ បើខ្ញុំថើបប្រពន្ធលោកវិញ ខ្ញុំមានអារម្មណ៍យ៉ាងណាយ៉ាងណីទេ!" បើលោកអ្នកចង់ជម្រាបសួរគ្នាទៅវិញទៅមកដោយថើបយ៉ាងបរិសុទ្ធ សូមធ្វើបែបនោះជាមួយនឹងភេទដូចគ្នាចុះ សូមកុំថើបឆ្លងភេទអោយសោះ ក្រែងលោភាពបរិសុទ្ធក្លាយទៅជាបរលើសោកវិញ។

**១៣"ពួកបរិសុទ្ធគ្រប់គ្នាសូមជំរាបសួរមកអ្នករាល់គ្នា ១៤"សូមឱ្យអ្នក**
**រាល់គ្នា បានប្រកបដោយព្រះគុណ នៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ**
**នឹងសេចក្តីស្រឡាញ់របស់ព្រះ ហើយនឹងសេចក្តីរួបរួមគ្នានឹង**

**ព្រះវិញ្ញាណបរិសុទ្ធ។ អាម៉ែន។ (២កូរិនថូស១៣:១៣-១៤)។**

នៅពេលសាវ័កប៉ុលមានប្រសាសន៍ថា សូមអោយអ្នករាល់គ្នាបានប្រកបដោយព្រះគុណនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងសេចក្តីស្រឡាញ់របស់ព្រះ ហើយនិងសេចក្តីរួបរួមគ្នានឹងព្រះវិញ្ញាណបរិសុទ្ធចុះ លោកបញ្ជាក់អំពីការប្រកបជាមួយនឹងអង្គព្រះត្រៃឯក ដែលមានព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ លោកចង់អោយក្រុមជំនុំទាំងអស់ រួមទាំងពួកជំនុំនៅទីក្រុងកូរិនថូសផង មានការប្រកបជាមួយនឹងព្រះត្រៃឯកដូចគ្នាដែរ។ ទាំងពួកជំនុំ ទាំងអ្នកជឿផ្ទាល់ខ្លួនត្រូវមានការប្រកបជាមួយនឹងព្រះគុណរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ប្រកបជាមួយនឹងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងសេចក្តីរួបរួមគ្នាក្នុងព្រះវិញ្ញាណ។

ខ្ញុំសូមបញ្ចប់ការសិក្សាគម្ពីរ២កូរិនថូសដោយបរិប្ទរតែត្រឹមណេះ។ ព្រះជាម្ចាស់ផ្តល់ព្រះគុណដល់យើងទាំងអស់គ្នា ដើម្បីអោយយើងអាចស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ ព្រមទាំងដើម្បីអោយខ្ញុំអាចចែកចាយព្រះបន្ទូលរបស់ព្រះអង្គ។ ដូច្នេះសូមព្រះជាម្ចាស់ទទួលនូវការថ្វាយបង្គំ ការតម្កើង ការសរសើរ ការអរព្រះគុណដល់ព្រះអង្គ ពីពួកយើងខ្ញុំ។ សូមព្រះជាម្ចាស់ប្រទានពរដល់បងប្អូនទាំងអស់គ្នា ពេលយើងកំពុងស្វែងរកធ្វើតាមបំណងរបស់ព្រះអង្គ នៅក្នុងជីវិតរបស់យើងរៀងរាល់ថ្ងៃ។ អាម៉ែន និងអាម៉ែន។